ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ　　**នាមនាមប្រជារាស្ត្រខ្មែរ**

លេខ : ២៧　　**តុលាការកំពូល**

ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៣

**សាលដីកា**

លេខ : ៥៣

ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៣

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ**　　ប្រធាន

២- លោក ឈឹម ស៊ីផល　　ចៅក្រម

៣- លោក ជីវ កេង　　ចៅក្រម

៤- លោក ប៉ែន សារឿន　　ចៅក្រមរបាយការណ៍

៥- លោក យស់ សូខឿន　　ចៅក្រម

ក្រឡាបញ្ជី

លោក សុខ ប៊ុនសង

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង　　អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ១២ "ច" ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០៣របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ២៧ ចុះថ្ងៃទី២២ ខែឧសភាឆ្នាំ២០០៣ របស់តុលាការកំពូល ។

**<u>ពិរុទ្ធ</u>** : ក្លែងលិខិត ប្រព្រឹត្តនៅភូមិព្រៃកថ្មី ឃុំ-ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩២ ។

- ជនជាប់ចោទឈ្មោះ ឈា តុងគ្រេង (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិ ខ្មែរ កើតនៅភូមិព្រែកតាងដូង ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ។ ទីលំនៅសព្វថ្ងៃភូមិ-ឃុំ ព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ឪពុកឈ្មោះឈា អ៊ាប "រស់" ម្តាយឈ្មោះកាន់ គី "រស់" ប្រពន្ធ ឈ្មោះប្រាក់ សុខុម មានកូន០៧នាក់ ទោសពីមុនគ្មាន ។

- មេធាវី លោក ពុធ ធាវី

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះកិ ណាត (ជាម្ចាស់បណ្ដឹងសាទុក្ខ) ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅភូមិព្រែកបិះ ឃុំកោះធំ"ខ" ស្រុកកោះធំ ខេត្តកណ្ដាល ឪពុកឈ្មោះ រ៉ុយ កិ "ស្លាប់" ម្ដាយឈ្មោះខា ឆេង "ស្លាប់" ប្រពន្ធឈ្មោះ ហ៊ាង ប៉ោណេង មានកូន០៤នាក់ ។

- មេធាវី លោក ជា ផេង

តាមពាក្យបណ្ដឹងចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៩ របស់ឈ្មោះថេង ហ៊ាង ប្ដឹងពីឈ្មោះ ឈា-តុងក្រេង ដែលបានក្លែងបន្លំមេដៃលើកំណត់ហេតុអង្កេតដីចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩២ ដោយសំអាងហេតុថា : កំណត់ហេតុអង្កេតដីរបស់ឈ្មោះឈា តុងក្រេង ពុំមែនស្នាមមេដៃ ឈា តុងក្រេង ទេ ឯស្នាមមេដៃរបស់ឈ្មោះថេង ហ៊ាង ក៏ពុំមែនរបស់ឈ្មោះថេង ហ៊ាង ដែរ សំណូមពរដាក់ទោសអ្នកក្លែងបន្លំមេដៃធ្វើប័ណ្ណកម្មសិទ្ធិលួចយកដីរបស់ខ្លួនតាមច្បាប់ ។ បដិសេធប័ណ្ណកម្មសិទ្ធិលួចយកដីរបស់ខ្លួនតាមច្បាប់ ។ បដិសេធប័ណ្ណកម្មសិទ្ធិ $E_2$ 0513 ចោល និង សងជម្ងឺចិត្តឱ្យខ្លួនចំនួន៣លានរៀល ។

- បានឃើញដីកាតំកល់រឿងទុកមិនចាត់ការលេខ០១៥ ដ ក មចក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ របស់តំណាងអយ្យការ អមតុលាការខេត្តកណ្ដាល ដែលមានសេចក្ដីសំរេចដូចតទៅ :

+បណ្ដឹងរបស់ឈ្មោះថេង ហ៊ាង ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៩ ផុតអាជ្ញាយុកាលព្រោះថ្ងៃប្រព្រឹត្តពីឆ្នាំ១៩៩២ ម្ល៉េះ ។

+សំរេចតំកល់រឿងនេះទុកមិនចាត់ការតទៅ ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ០២ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ របស់ឈ្មោះ កិ ណាត ប្ដឹងមិនសុខចិត្តនឹងដីកាតំកល់រឿងទុកមិនចាត់ការលេខ០១៥ ដ ក មចក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ របស់តំណាងអយ្យការ អមតុលាការខេត្តកណ្ដាល លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា :

១-ទទួលបណ្ដឹងឧទ្ធរណ៍លេខ០២ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០របស់ដើមបណ្ដឹង កិ ណាត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោល ដោយទាស់នឹងគតិច្បាប់ ។

២-តំកល់ដីកាតម្កល់រឿងទុកមិនចាត់ការលេខ០១៥ ចុះថ្ងៃទី១៤ខែតុលាឆ្នាំ២០០០ របស់អយ្យការខេត្តកណ្ដាលទុកជាបានការ ។

- បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ១២"ច" ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-មិនទទួលជំនុំជំរះលើបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ដោយបណ្ដឹងឧទ្ធរណ៍នេះធ្វើឡើងហួសកំណត់ច្បាប់ ។

២-ចំណាយសំណុំរឿងព្រហ្មទណ្ឌលេខ៣៦៦ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ចេញពីបញ្ជីក្ដីរបស់សាលាឧទ្ធរណ៍ ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ១០ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះ កិ ណាត ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ១២"ច" ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលា-ឧទ្ធរណ៍ នៃសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណា ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់ម្ចាស់បណ្តឹងសាទុក្ខធ្វើឡើងត្រឹមត្រូវតាតកំណត់ច្បាប់ ។

- បានឃើញសារណាតប ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៣ របស់ចុងបណ្តឹងសាទុក្ខ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ អមតុលាការកំពូលថា :ឈ្មោះ ចេង ហ៊ង ពិតជាបានទទួលលិខិតជូនដំណឹងនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ហើយក៏បានចូលមកប្តឹងឧទ្ធរណ៍នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ដែលមានលិខិតបញ្ជាក់បំភ្លឺរបស់លោកព្រះរាជអាជ្ញា តុលាការខេត្តកណ្តាល ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ចោលជាអសារបង់ ។

- ក្រឡាបញ្ជីអានសាវតាជាតិ និងសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី( ម្ចាស់បណ្តឹងសាទុក្ខ)

បានស្តាប់ចម្លើយរបស់ឈ្មោះ ឈា តុងក្រេង នៅពេលជំនុំជំរះថា :

+ លិខិតចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩២គឺជាលិខិតអង្កេតវាស់វែងដីធ្លីរបស់ខ្ញុំពិតប្រាកដមែន ប៉ុន្តែលិខិតនេះបានធ្វើក្រោយលិខិតចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩២ ជាលិខិតដីធ្លីរបស់ឈ្មោះ ចេង ហ៊ង ជាឪពុក កិ ណាត ដែលមានព្រំខាងត្បូងជាប់ដីរបស់ខ្ញុំ ។

នៅសម័យនោះជាសម័យយុទ្ធនាការ ការវាស់វែងអង្កេតដី ខ្ញុំពឹងលើស្វ័រយោដីទាំងស្រុង ពេលនោះ ចេង ហ៊ង ក៏បានផ្តិតមេដៃលើកំណត់ហេតុវាស់វែងដីនោះដែរ ម្តេចមិនតវ៉ានៅពេលនោះ ទើបតែពេលនេះប្តឹង គឺវាខុសនឹងអាជ្ញាយុកាលទៅហើយ ដែលព្រះរាជអាជ្ញាបានចេញដីកាតម្កល់រឿងមិនចាត់ការនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០០ តែបណ្តឹងឧទ្ធរណ៍របស់ចេង ហ៊ង ធ្វើនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ នេះជាការហួសបណ្តឹងឧទ្ធរណ៍ ដូច្នេះខ្ញុំសូមតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ដដែល ។

- បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោកជា ជេង ជាមេធាវីអោយដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសវនាការថា : ដោយការចុះបណ្តឹងឧទ្ធរណ៍ គ្មានសៀវភៅចុះត្រឹមត្រូវទេ ដែលក្រឡាបញ្ជីចុះបណ្តឹងឈ្មោះ អ៊ា ធឿន លុះដល់ហត្ថលេខា និង ចុះហត្ថលេខាចម្លងចេញ គឺឈ្មោះឈាវ រិនឌី ទៅវិញ ឃើញថាវាខុសនឹងនីតិវិធីក្នុងការចុះបណ្តឹងឧទ្ធរណ៍ទៅហើយ ដែលកូនក្តីខ្ញុំបានសរសេរពាក្យ

បណ្តឹងទៅផ្ទះបោះដៃនៅថ្ងៃទី០៧ខែមេសាឆ្នាំ២០០០ ក្រោយពីបានទទួលដំណឹងរយៈពេលមួយខែ តែសាលាឧទ្ធរណ៍ពិនិត្យតែសេចក្តីប្តឹង ដូច្នេះខ្ញុំសូមតុលាការបដិសេធសាលដីកាសាលាឧទ្ធរណ៍ ចោលជាអសារបង់ ។

- បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក ពុធ ធារី ជាមេធាវីការពារឱ្យជនជាប់ចោទនៅពេលសវនាការថា :រឿងនេះវាមិនពាក់ព័ន្ធទៅលើរឿងចាត់ការ ឬមិនចាត់ការនោះទេ គឺជារឿងហួសបណ្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ ព្រោះឈ្មោះចេង ហ៊ង បានប្តឹងឧទ្ធរណ៍ហួសកំណត់ច្បាប់ រឿងថាខ្លួនបានប្តឹងត្រឹមត្រូវក្នុងកំណត់ច្បាប់ ហើយក្រឡាបញ្ជីធ្វើឱ្យខុសនីតិវិធីបណ្តឹង នោះជារឿងរបស់ក្រឡា-បញ្ជីតែប៉ុណ្ណោះ គួរតែឈ្មោះចេង ហ៊ង ទៅប្តឹងពីក្រឡាបញ្ជីនោះទៅ ដែលគ្មានទាក់ទងក្តីដល់ប្រយោជន៍កូនក្តីខ្ញុំទេ ដូច្នេះសូមតម្កល់សាលដីការបស់សាលាឧទ្ធរណ៍អោយនៅដដែល ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ ថា : គេមិនអាចប្តឹងឧទ្ធរណ៍នៅទីណាបានទេ ក្រៅពី ក្រឡាបញ្ជីចុះបណ្តឹងឧទ្ធរណ៍ បើប្តឹងនៅថ្ងៃ ខែ ឆ្នាំ ណា ត្រូវតែចុះថ្ងៃ ខែ ឆ្នាំ នោះឱ្យគេដូច្នេះការខុស ឆ្គងរបស់ក្រឡាបញ្ជី ត្រូវតែឱ្យមានចាត់ការលើបណ្តឹងឧទ្ធរណ៍ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់លោក កិ ណាត ចម្លើយជនល្មើសឈ្មោះ ឈា តុងក្រេង និងសេចក្តីសន្និដ្ឋានការពាររបស់ដើមបណ្តឹងរដ្ឋប្បវេណី និង ជនល្មើស
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១០ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះ កិ ណាត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចលើកបណ្តឹងឧទ្ធរណ៍របស់លោកកិ ណាត ចោលដោយអាងហេតុថា បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ របស់លោកធ្វើឡើងហួសកំណត់ច្បាប់នោះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា :

ក/លោកកិ ណាត បានទទួលដំណឹងនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០០ អំពីដីកាតម្កល់រឿងទុកមិនចាត់ការលេខ០១៥ ដ.ក.អ.ក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ របស់អយ្យការ អមតុលាការខេត្តកណ្តាល លោកកិ ណាត បានប្តឹងឧទ្ធរណ៍នៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ និងបានផ្តិតមេដៃទុកនៅការិយាល័យអយ្យការផងដែរ ដូច្នេះបណ្តឹងឧទ្ធរណ៍នេះមិនទាន់ហួសកំនត់ច្បាប់ទេ ។

ខ/កាលបរិច្ឆេទថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ពុំមែនជាកាលបរិច្ឆេទដែលលោក កិ ណាត ប្តឹងឧទ្ធរណ៍ទេ គឺជាការបរិច្ឆេទដែលបានចម្លងសេចក្តីសុំប្តឹងឧទ្ធរណ៍លេខ០២ ដែលគ្មានចុះថ្ងៃ ខែ ឆ្នាំ ។ ដូច្នេះសាលាឧទ្ធរណ៍ ពុំអាចយកថ្ងៃ ខែ ឆ្នាំ នេះធ្វើជាថ្ងៃ ខែ ឆ្នាំ ប្តឹងឧទ្ធរណ៍បានទេ ។

គ/លិខិតលេខ៤២៦ ចុះថ្ងៃទី១៤ កែកក្កដា ឆ្នាំ២០០០ របស់អយ្យការខេត្តកណ្តាល គឺលិខិតដែលមានស្នាមលប់សរសេរលេខថ្ងៃ និង ខែ ថ្មីពីលើស្នាមលប់ ដូច្នេះលិខិតនេះមិនអាចយកជាការបានឡើយ ។ ប៉ុន្តែលិខិតលេខ២១៤ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ដែលព្រះរាជអាជ្ញា អមតុលាការខេត្តកណ្តាល ផ្ញើជូនជាឯកសារ ដែលមានខ្លឹមសារផ្ញើសំណុំរឿងដែលត្រូវប្តឹងឧទ្ធរណ៍មកសាលាឧទ្ធរណ៍ បង្ហាញឱ្យឃើញថា ទាំងថ្ងៃ ខែ ឆ្នាំ ដែលលោកកិ ណាត ប្តឹងឧទ្ធរណ៍ ទាំងថ្ងៃ ខែ ឆ្នាំ ដែលព្រះរាជអាជ្ញាផ្ញើសំណុំរឿងជូនអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍មានភាពស៊ីសង្វាក់គ្នា ហើយស្ថិតនៅក្នុងកំណត់ច្បាប់ស្តីពីបណ្តឹងឧទ្ធរណ៍ទាំងអស់ ។

- យល់ឃើញថា ការសំរេចតម្កល់រឿងទុកមិនចាត់ការ របស់តំណាងអយ្យការអមតុលាការខេត្តកណ្តាល ដោយអាងហេតុថា ហួសអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ក្នុងបទល្មើសក្លែងនោះជាការពុំត្រឹមត្រូវទេ ពីព្រោះឯកសារដែលដើមបណ្តឹងរដ្ឋប្បវេណីយកធ្វើជាកម្មវត្ថុបណ្តឹងពីបទក្លែងស្នាមមេដៃនោះ ឈ្មោះឈា តុងក្រេង កំពុងតែយកមកប្រើប្រាស់តាំងពីតុលាការខេត្តកណ្តាល សាលាឧទ្ធរណ៍ រហូតដល់តុលាការកំពូលក្នុងរឿងរដ្ឋប្បវេណីហើយពុំទាន់ត្រូវបានបញ្ចប់នៅឡើយទេ ។ បទល្មើសប្រើប្រាស់លិខិតក្លែងនេះក៏ត្រូវបានច្បាប់ផ្តន្ទាទោសដូចបទល្មើសក្លែងដែរ ។ ដូច្នេះព្រះរាជអាជ្ញាដែលជាម្ចាស់បណ្តឹងអាជ្ញា មានភារកិច្ចធ្វើបណ្តឹងអាជ្ញាតាមមាត្រា២នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និង មាត្រា៨នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាកាលបើបានឃើញបទល្មើសមួយហើយ មិនអាចទុកបទល្មើសនោះចោលមិនធ្វើការចោទប្រកាន់បានទេ ។

- យល់ឃើញថា តុលាការកំពូលជំនុំជំរះនៅពេលនេះ គឺទាក់ទងនឹងដីកាតម្កល់រឿងទុកមិនចាត់ការដែលជារឿងមុនអង្គសេចក្តី ។ ដូច្នេះនីតិវិធីនៃការជំនុំជំរះនៃរឿងមុនអង្គសេចក្តី គឺពុំត្រូវបានអនុញ្ញាតឱ្យបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ទេ ។ តុលាការកំពូលបើយល់ថា សាលដីកាសាលាឧទ្ធរណ៍ត្រឹមត្រូវ សំរេចថាតម្កល់ទុកជាបានការ បើយល់ថាខុសសម្រេចទុកមោឃៈដោយឥតបង្វិលតែម្តងដើម្បីចៀសវាងការអូសបន្លាយពេលវេលារឿងក្តីដល់រឿងអង្គសេចក្តី ។

- យល់ឃើញថា លោកកិ ណាត បានធ្វើសារណាជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះតុលាការកំពូលជំនុំជំរះកំបាំងមុខចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១២"ច" ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលសំរេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទំរង់ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដីចំពោះមុខជនល្មើស ឈា តុងគ្រេង**

**តំណាងមុខឈ្មោះ កិ ណាត ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្ដឹងសាទុក្ខលេខ១០ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះ កិ ណាត ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ១២"ច" ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ទាំងមូលដោយឥតបង្វិល ។

៣-ទុកជាមោឃៈដីកាតំកល់រឿងទុកមិនចាត់ការលេខ០១៥ចុះថ្ងៃទី១៤ខែមករាឆ្នាំ២០០៣ របស់អយ្យការ អមតុលាការខេត្តកណ្ដាល ។

៤-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ២៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៣ របស់តុលាការកំពូលទៅអយ្យការ អមតុលាការខេត្តកណ្ដាល ដើម្បីធ្វើការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។

៥-សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៣ ។